**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៥៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ចំណូល និង ការបែងចែកចំណាយមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៥០អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគ្រឹះស្ថានអង្គរជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

អនុញ្ញាតឱ្យប្រើប្រាស់ចំណូលចំនួន១៥%(ដប់ប្រាំភាគរយ) នៃចំណូលដុលប្រចាំឆ្នាំរបស់ "គ្រឹះស្ថានអង្គរ "ដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ ជា**មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ** ។

**មាត្រា២.-**

ចំណាយ **មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ** ត្រូវបានគ្រោងជាចំណាយមិនទាន់បែងចែកមានមុខសញ្ញារបស់រាជរដ្ឋាភិបាល នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ សម្រាប់បែងចែកដល់គោលដៅនៃការប្រើប្រាស់ប្រចាំឆ្នាំ តាមអត្រាដូចខាងក្រោម÷

១.អាជ្ញាធរអប្សរា ចំនួន៧៧% សម្រាប់ជាគុណប្រយោជន៍ក្នុងការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។ អាជ្ញាធរអប្សរា ត្រូវប្រើប្រាស់មូលនិធិនេះមួយចំនួនសម្រាប់ការអភិវឌ្ឍប៍តំបន់ប្រាសាទព្រះវិហារ។

២. សាលាខេត្តសៀមរាប ចំនួន១០% ដើម្បីធ្វើការអភិវឌ្ឍបន្ថែមសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅជុំវិញតំបន់អង្គរ និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប។

៣. ក្រសួងទេសចរណ៍ ចំនួន៥% ក្នុងគោលដៅបង្កើតផលិតផលទេសចរណ៍ថ្មីៗបន្ថែមទៀតដើម្បីរញ្ញសក្តានុពលទេសចរណ៍កម្ពុជា និង កំណើនសេដ្ឋកិច្ច។

៤. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំនួន៥% ដើម្បីធ្វើការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ ទាំងរូបិយ និងអរូបិយ។

៥. អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ចំនួន៣% ដើម្បីបែងចែកជូនដល់អង្គភាពនគរបាលទេសចរណ៍ ដោយផ្អែកលើផែនការច្បាស់លាស់ស្របតាមគោលនយោបាយអភិវឌ្ឍវិស័យ ទេសចរណ៍ ដើម្បីជួយដល់អង្គភាពនគរបាលទេសចរណ៍តាមគោលដៅសំខាន់ៗ ក្នុងការលើកកំពស់សមត្ថភាព ប្រសិទ្ធិភាពនៃការថែរក្សាសុវត្ថិភាព និងសន្តិសុខជូនភ្ញៀវទេសចរ ដែលជាកត្តាមិនអាចខ្វះបានដើម្បីការពារ និង ទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។

**មាត្រា៣.-**

ចំណាយ **មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ** ស្ថិតក្រោមការគ្រប់គ្រង និងបញ្ជាផ្ទាល់របស់ប្រមុខរាជរដ្ឋាភិបាល តាមរយៈបរិបទចំណាយនៃថវិការដ្ឋ ។

ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដូចចែងក្នុងមាត្រា២ ត្រូវរៀបចំផែនការសកម្មភាពការងារ និងគម្រោងចំណាយជាក់លាក់ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ លើមូលដ្ឋាននៃចំណូលរបស់គ្រឹះស្ថានអង្គរមុនឆ្នាំកំពុងអនុវត្តថវិកាមួយឆ្នាំ ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ទេរឥណទានប្រចាំឆ្នាំជូនក្រសួង និងស្ថាប័នពាក់ព័ន្ធ ដោយអនុក្រឹត្យដោយឡែក ដើម្បីអនុវត្តគម្រោង និងសកម្មភាពការងារទៅតាមទំហំថវិកាដែលប្រមុខរាជរដ្ឋាភិបាលបានអនុម័ត។

**មាត្រា៤.-**

ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដែលទទួលបាន**មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ** ត្រូវបានផ្តល់សិទ្ធិស្វ័យសម្រេចនិងការទទួលខុសត្រូវពេញលេញលើការអនុវត្តចំណាយ។ នីតិវិធីលម្អិតសម្រាប់អនុវត្តចំណាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គ្រឹះស្ថានអង្គរ អាជ្ញាធរអប្សរា សាលាខេត្តសៀមរាប និង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ